**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

**លេខ : ០២៩ សណន**

រាជធានីភ្នំពេញ. ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩

# សេចក្តីណែនាំ

## ស្តីអំពី

## ទីកន្លែងហាមជក់បារី

យោងតាមខ្លឹមសារ នៃលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១២៧០ សជណ.អវ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីអំពីគោលការណ៍ហាមជក់បារីនៅកន្លែងធ្វើការរបស់មន្ត្រីរាជការ សាលប្រជុំ រោងមហោស្រព និងយោងតាមស្មារតីអង្គសិក្ខាសាលា កាលពីថ្ងៃទី ១៤ - ១៧ - ១៨ - ២១ ខែ កញ្ញា ឆ្នាំ ២០០៧ ដែលបានបង្ហាញឱ្យឃើញអំពីផលវិបាកនៃការជក់បារីនិងស្រូបផ្សែងបារីពីអ្នកជក់ ដែលបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពសាធារណជន បរិស្ថាន ធ្វើឱ្យបាត់បង់ថវិកាគ្រួសារ និងសេដ្ឋកិច្ចជាតិទៀតផង ។

ក្រសួងមហាផ្ទៃសូមធ្វើការណែនាំ ចំពោះអាជ្ញាធររាជធានី ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួងដូចខាងក្រោម :

១-ហាមជក់បារីនៅក្នុងអាគារធ្វើការ បន្ទប់ធ្វើការរបស់មន្ត្រីរាជការ ក្នុងទីស្តីការក្រសួង ក្នុងអាគារធ្វើការ បន្ទប់ធ្វើការរបស់មន្ត្រីរាជការក្នុងសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សាលប្រជុំ បន្ទប់ទឹក និង តាមផ្លូវដើរចេញចូលនៃអាគារធ្វើការរបស់មន្ត្រីរាជការ ។

២-ទីកន្លែងខាងលើនេះ ត្រូវអនុវត្តដូចតទៅ :

-បិទផ្លាកហាមជក់បារី

-បិទរូបភាពផ្សព្វផ្សាយ អប់រំស្តីពីប៉ះពាល់ដល់សុខភាពដោយការជក់បារី

-ត្រូវចូលរួមធ្វើការអប់រំ ស្តីអំពីផលប៉ះពាល់សុខភាពដោយសារការប្រើប្រាស់ថ្នាំជក់ ដើម្បីទប់ស្កាត់ ឬកាត់បន្ថយការជក់បារីរហូតឈានដល់ការលះបង់ទំលាប់ជក់បារីទាំងស្រុង ។

៣-ក្នុងករណីមានការប្រព្រឹត្តផ្ទុយពីសេចក្តីណែនាំ ដែលបានរៀបរាប់ខាងលើ ត្រូវទទួលការណែនាំពីប្រធានអង្គភាពសាមី ។

ពេលទទួលបាននូវសេចក្តីណែនាំនេះ ឯកឧត្តមអភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ មានភារកិច្ចអនុវត្ត ឱ្យទទួលបានប្រសិទ្ធភាព ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**__ចម្លងជូន__** :

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងពាក់ព័ន្ធ

-អង្គភាពក្រៅរដ្ឋាភិបាលពាក់ព័ន្ធ

-មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព

" ដើម្បីជ្រាបជ្រាប "

-គ្រប់សាលារាជធានី ខេត្ត

-គ្រប់អង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ

" ដើម្បីអនុវត្ត និងណែនាំបន្ត "

-ឯកសារ កាលប្បវត្តិ

-